ហេតុអ្វី មានការសម្របសម្រួល ?



ហេតុអ្វី មាន ការសម្របសម្រួល ?

វាគ្មានអ្វី ដែលអាចចាត់ទុកបានថា មាន សម្ថានភាព នៃវីរកម្ម (geste) របស់បនក្ខំពេញនោះឡើយ។ ការដោះលែងអ្នកទោសនយោបាយក្តី អ្នកទោសមនសិការក្តី សុទ្ធជាល្បិច ដែលពួកកុម្មុយនិស្ត តែងតែយកមកប្រើ កាលណាវាយល់ថា កម្លាំងបច្ចាមិត្ត ខ្លាំងជាង កម្លាំងវាពេក ឬក៏ វាគ្មានមធ្យោបាយ កំទេចដើម្បី យកជ័យជំនះ។ ក្នុងកាល:ទេស:បែបនេះ ពួកកុម្មុយនិស្ត ត្រូវតែបង្ខំចិត្តអនុវត្តន៏ ការសម្របសម្រួលជាមួយបច្ចាមិត្ត តែជាការបណ្តោះអាសន្នទេ គឺជាស្ពានសម្រាប់ឆ្លងពីតំណាក់ការមួយ ទៅដំណាក់ការមួយទៀត ដើម្បីរង់ចាំការរៀបចំរបស់វា អោយបានតឹងជើងរឹងដៃតែប៉ុណ្ណោះ។ កាលណាកម្លាំងពួកវា បានចេញពីដំណាក់ការ កុន « ចុះ » មកដំណាក់ការ « ឡើង » វាត្រូវប្តូរយុទ្ធសាស្ត្រ និង កលយុទ្ធភ្លាម វាចាប់យក បន្ទាត់សកម្មភាពត្រង់តែម្តង ដោយ ប្តូរការសម្របសម្រួលមក ការមិនព្រមសម្របសម្រួលវិញ។ គឺ របៀបនេះ ហើយ ដែលពួកកុម្មុយនិស្ត តែងតែអនុវត្តរឿយៗ ស្របតាមការឡើង ឬ ការចុះ នៃស្ថានភាពនយោបាយ។ ការសម្របសម្រួល របស់ពួកកុម្មុនិស្ត ជាមួយបច្ចាមិត្ត អាចអោយវាបន្ធូរការសង្កិតសង្កិនពីសំណាក់ត្រូវវា ដើម្បី អាចអោយវាមាន

ហេតុអ្វី មានការសម្របសម្រួល ?

ពេលសំរាក និង ជៀសវាងបរាជ័យ យ៉ាងអាម៉ាស់ និង ជូចត់។ ការឆ្លៀតយកពេលនេះ ដើម្បី ធ្វើអោយផ្ទៃក្នុង របស់បក្ខាមិត្តវា មាន បសិវាទកម្ម មានការបែកបាក់សាមគ្គីគ្នា ធ្វើអោយសត្រូវវាចុះខ្សោយ សំរាប់ជាឱកាសអោយវាវាយសម្លាប់តែម្តង។ ជាឧទាហរណ៍ ពួកកុម្មុនិស្តរុស្សី សុខចិត្តចូលរួមធ្វើសហប្រតិបត្តិការជាមួយស្តេច TSAR វិញ ក្រោយពីវាបានទទួលបរាជ័យជាលើកដំបូងនៅឆ្នាំ ១៩០៥។ យួនកុម្មុយនិស្ត សុខចិត្តចរចាជាមួយសហរដ្ឋអាមេរិក រហូតមានចុះហត្ថលេខា ដើម្បីសន្តិភាពនៅឆ្នាំ ១៩៧៣ ។ល។

ពិតណាស់ហើយថា ខ្មែរយើង មានការក្រេកអរនឹង ការដោះលែង ជនរងគ្រោះទាំងឡាយ ដែលគ្មានទោសសោះ តែ ប នក្នុំពេញ បានចាប់ដាក់ពន្ធនាគារ ដោយអយុត្តិធម៌ ជាទីបំផុត ហើយ គេដោះលែងវិញ ក្រោយពីបានរស់នៅក្នុងគុកអស់កាលដ៏យូរលង់ បន្ទាប់ពី បានធ្វើលិខិតផ្ទាល់ខ្លួន រៀងខ្លួនៗ ទទួល កំហុស និង សូមទោស ដល់មេបន ឬ នាយបងធំ។ តែខ្មែរយើង មិនត្រូវទទួលស្គាល់ ការដោះលែងនេះ ជាវិរកម្ម ប្រកបដោយសម្ថានចិត្ត របស់បនក្នុំពេញនោះឡើយ ព្រោះ វាជាល្បិចខូច របស់ពួកវា ដែលបានរៀបរាប់ខាងលើនេះ។ ហើយត្រូវដឹងទៀតថា ការដោះលែងនេះ វាគ្រាន់តែជា ការព្យួរទោសតែប៉ុណ្ណោះ មិនមែនជាការលុបទោសនោះឡើយ។ ដូច្នេះ ចូលរួមស្វាគមន៍ ចំពោះអ្នករងគ្រោះ និង គ្រួសារ គឺ « បាទ ឬ ចាស »

ហេតុអ្វី មានការសម្របសម្រួល ?

តែ អគុណ ចំពោះ បនភ្នំពេញ គឺ « ទេ ឬ ក្ខាន » ព្រោះវាជា គោលការណ៍ នៃ យុត្តិធម៌ និង សីលធម៌។ យើងពុំអាច អគុណ ដល់ជនទុច្ចរិតបាននោះឡើយ ព្រោះជនទុច្ចរិត ត្រូវទទួល ទោសតាមច្បាប់ជាធរមាន និង បន្ទោស តាមផ្លូវសីលធម៌, បើ ពុំនោះទេ វាលែងមានអ្វី ដែលជា កុសល និង អកុសល នៅក្នុង សង្គមខ្មែរតែម្តង។ ជាឧទាហរណ៍ : ចោរ ចាប់មនុស្ស ជាចំណាត់ ខ្មាំង ហើយ សម្លាប់បីនាក់ តែដោះលែង ដប់នាក់ មិនមែនជា ចោរឃាតករល្អនោះទេ គឺវានៅតែជា ចោរឃាតករ ដដែល។ ក្រៅ អំពើដែលបនភ្នំពេញ បានប្រព្រឹត្ត មិនអាចមាន ស្ថាន ភាព បន្ធូរបន្ថយ (circonstance atténuante) នោះទេ។ អ្វីដែល ពួកគេធ្វើ គឺធ្វើនៅក្នុងល្បិចខូច មានការពិចារណាជានិច្ច ដើម្បី អោយប្រជាពលខ្មែរ និង សត្រូវនយោបាយ របស់វា ធ្លាក់ ក្នុងការភ្លេចភ្លាំង និង ពិការស្មារតី។

ចំពោះពួកកុម្មុយនិស្ត គឺ « មិត្តនៅថ្ងៃនេះ គឺ សត្រូវនៅថ្ងៃ ស្អែក » ហើយ កលយុទ្ធបង្ហួបបង្ហួម និង កលយុទ្ធវាយប្រហារ នេះ ជារបៀបដែលកុម្មុយនិស្ត ជ្រើនប្រើជាងគេបំផុត ក្នុងការ ប្រយុទ្ធរបស់វា ប្រឆាំងនិងបច្ចាមិត្ត៖